ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៣១៣៤ មស.សណ

# សេចក្ដីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន ប្រធានអង្គភាពនានាចំណុះក្រសួង និងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ មេត្តាជ្រាបថា អនុវត្តតាមអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ស្ដីពីការកែសម្រួលរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អង្គភាពចំណុះក្រសួងមុខងារសាធារណៈ ក្រសួងនឹងដំណើរការពិនិត្យវាយតម្លៃតាមបែបគុណាធិបតេយ្យ ដើម្បីជ្រើសរើសមន្ត្រី ដែលមានលក្ខណៈសម្បត្តិសមស្របឱ្យទទួលមុខតំណែងទំនេរជាអនុប្រធាននាយកដ្ឋាន និងប្រធានការិយាល័យក្នុងរចនាសម្ព័ន្ធដែលបានកែសម្រួល។

ក្នុងន័យនេះ ដើម្បីផ្ដល់ឱកាសដល់មន្ត្រីរាជការបម្រើការងារក្រសួង ដែលមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ ហើយមានបំណងចង់ចូលរួមចំណែកបំពេញការងារស្របតាមតម្រូវការ តួនាទី ភារកិច្ចខាងលើ សូមប្រធានអង្គភាពនានាចំណុះក្រសួង មេត្តាផ្សព្វផ្សាយ ជូនដំណឹងឱ្យបានទូលំទូលាយដល់មន្ត្រីក្រោមឱវាទដែលមានការចាប់អារម្មណ៍ មកដាក់ពាក្យស្នើសុំចូលរួមតាមរយៈនាយកដ្ឋានគ្រប់គ្រងបុគ្គលិកនៅទីស្ដីការក្រសួងមុខងារសាធារណៈ ចាប់ពីពេលជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១។

លក្ខខណ្ឌនៃការជ្រើសរើស៖

- សញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើង
- បទពិសោធន៍ការងារចាប់ពី ៣ឆ្នាំ ទៅ ៥ឆ្នាំឡើង

បេក្ខជនទាំងអស់ត្រូវឆ្លងកាត់ដំណើរការពិនិត្យ វាយតម្លៃ សម្ភាសន៍ និងចម្រាញ់សម្រេចចុងក្រោយដោយគណៈកម្មការជ្រើសរើសរបស់ក្រសួង។

ព័ត៌មានលំអិតបន្ថែម សូមធ្វើទំនាក់ទំនងជាមួយនាយកដ្ឋានគ្រប់គ្រងបុគ្គលិកនៅទីស្ដីការក្រសួងមុខងារសាធារណៈ (លេខទូរស័ព្ទ ០១២ ៨៥៨ ៨៣៣ និង ០១៦ ២០២ ៤៨៨)។

ថ្ងៃ ចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១
ត.ប. **រដ្ឋមន្ត្រី**
**អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ**

**ហាស់ ប៊ុនថ្លុន**